# សុន្ទរកថាស្វាគមន៍
# របស់អគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន
# ឧបនាយករដ្ឋមន្ត្រី, រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
# ថ្លែងក្នុង
# ពិធីប្រកាសដាក់ឱ្យដំណើរការជាផ្លូវការ
# «កម្មវិធីឧបត្ថម្ភសាច់ប្រាក់ជូនគ្រួសារក្រីក្រ និង ងាយរងគ្រោះ ក្នុងអំឡុងពេលជំងឺកូវីដ-១៩»

## រាជធានីភ្នំពេញ, ថ្ងៃទី ២៤ ខែ មិថុនា ឆ្នាំ ២០២០

- ខ្ញុំសូមសម្ដែងនូវគារវកិច្ចដ៏ខ្ពង់ខ្ពស់បំផុត គោរពជូនចំពោះ **សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា**;
- សម្ដេច, ឯកឧត្ដម, លោកជំទាវ, សមាជិក-សមាជិកា នៃរាជរដ្ឋាភិបាល;
- ឯកឧត្ដម, លោកជំទាវ, លោក, លោកស្រី តំណាងអង្គទូត និង ដៃគូអភិវឌ្ឍន៍;
- ឯកឧត្ដម, លោកជំទាវ, លោក, លោកស្រី, ភ្ញៀវកិត្តិយសទាំងអស់!

ខ្ញុំពិតជាមានសេចក្ដីសោមនស្សយ៉ាងក្រៃលែង ដែលមានកិត្តិយសស្វាគមន៍ សម្ដេច, ឯកឧត្ដម, លោកជំទាវ, លោក, លោកស្រី នៅក្នុងពិធីប្រកាសដាក់ឱ្យដំណើរការជាផ្លូវការ នូវ **«កម្មវិធីឧបត្ថម្ភសាច់ប្រាក់ជូនគ្រួសារក្រីក្រ និង ងាយរងគ្រោះ ក្នុងអំឡុងពេលជំងឺកូវីដ-១៩»** នាថ្ងៃនេះ ។ ជាបឋម, ខ្ញុំសូមសម្ដែងនូវគារវកិច្ចស្វាគមន៍ និង អំណរគុណយ៉ាងជ្រាលជ្រៅបំផុតចំពោះវត្តមានដ៏ឧត្តុងឧត្តមរបស់ **សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** ដែលបានចំណាយពេលវេលាដ៏មមាញឹក អញ្ជើញជាអធិបតីដ៏ខ្ពង់ខ្ពស់ ក្នុងកម្មវិធីនាព្រឹកនេះ ។ ខ្ញុំក៏សូមសម្ដែងនូវអំណរគុណផងដែរ

ចំពោះវត្តមានរបស់សម្តេច, ឯកឧត្តម, លោកជំទាវ, លោក, លោកស្រី តំណាងក្រសួង-ស្ថាប័ន របស់រាជរដ្ឋាភិបាល ក៏ដូចជាតំណាងអង្គទូត និង ដៃគូអភិវឌ្ឍន៍នានា ដែលបានអញ្ជើញចូលរួមក្នុងកម្មវិធីដ៏មានសារៈសំខាន់នេះ ។

ដូចសម្តេច, ឯកឧត្តម, លោកជំទាវ, លោក, លោកស្រី ជ្រាបស្រាប់ ជំងឺកូវីដ-១៩ មិនត្រឹមតែបង្កការគំរាមកំហែងដល់សុខភាព និង អាយុជីវិតរបស់ប្រជាពលរដ្ឋប៉ុណ្ណោះទេ តែក៏ថែមទាំងបង្កើតឡើងនូវផលអវិជ្ជមានជាច្រើន ដល់សេដ្ឋកិច្ច និង សង្គមជាតិទាំងមូលផងដែរ ។ ទោះជាយ៉ាងណា, ក្រោមការដឹកនាំដ៏ឈ្លាសវៃ, ប៉ិនប្រសប់, ម៉ឺងម៉ាត់ និង ប្រាកដនិយមរបស់ **សម្តេចតេជោនាយករដ្ឋមន្ត្រី**, កម្ពុជាអាចគ្រប់គ្រងសភាពការណ៍បានល្អ និង បានកាត់-បន្ថយផលប៉ះពាល់ជាអវិជ្ជមាននេះ ឱ្យស្ថិតនៅក្នុងរង្វង់ដែលអាចគ្រប់គ្រងបាន តាមរយៈការ-ដាក់ចេញនូវវិធានការចាំបាច់ខាងផ្នែកសង្គម-សេដ្ឋកិច្ច ជាបន្តបន្ទាប់ ។

នៅក្នុងក្របខណ្ឌនេះ, **សម្តេចតេជោ នាយករដ្ឋមន្ត្រី** បានផ្តោតការយកចិត្តទុក-ដាក់ជាពិសេស ចំពោះទុក្ខលំបាករបស់ប្រជាពលរដ្ឋ ដែលទទួលរងផលប៉ះពាល់ដោយសារជំងឺកូវីដ-១៩ ។ ក្រោមការចង្អុលបង្ហាញដ៏ខ្ពង់ខ្ពស់របស់ **សម្តេចតេជោ នាយករដ្ឋមន្ត្រី**, គណៈកម្មាធិការគោលនយោបាយសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ បានបង្កើតក្រុមការងារចំពោះកិច្ចដើម្បីសិក្សាអំពីលទ្ធភាព និង យន្តការសំដៅជួយសម្រាលដល់ការលំបាករបស់ប្រជាពលរដ្ឋដែលជាលទ្ធផល យើងបានរចនាដាក់ចេញនូវកម្មវិធីជំនួយសង្គមថ្មីមួយ គឺ : «**កម្មវិធីឧបត្ថម្ភសាច់ប្រាក់ជូនគ្រួសារក្រីក្រ និង ងាយរងគ្រោះ ក្នុងអំឡុងពេលជំងឺកូវីដ-១៩**» ដែលជាកម្មវត្ថុនៃការប្រកាសដាក់ឱ្យដំណើរការជាផ្លូវការនាថ្ងៃនេះ ។

ក្នុងនាមក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ដែលជាសេនាធិការបច្ចេកទេស បំពេញការងារនៅក្រោមការគ្រប់គ្រង និង ចង្អុលបង្ហាញដោយផ្ទាល់ របស់ **សម្តេចតេជោនាយករដ្ឋ-មន្ត្រី**, ក្នុងឋានៈ **សម្តេច** ជា **នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** និង ជា **អគ្គមេបញ្ជាការតែមួយ** ក្នុងការគ្រប់គ្រងហិរញ្ញវត្ថុ និង សេដ្ឋកិច្ចជាតិ, ខ្ញុំសូមគូស-បញ្ជាក់ថា «**កម្មវិធីឧបត្ថម្ភសាច់ប្រាក់ជូនគ្រួសារក្រីក្រ និង ងាយរងគ្រោះ ក្នុងអំឡុងពេលជំងឺកូ-វីដ-១៩**» នេះ អាចដាក់ឱ្យដំណើរការទៅបាន គឺដោយសារសមិទ្ធផលល្អប្រសើរនៃការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈរបស់រាជរដ្ឋាភិបាល ពិសេស គឺដោយសារលទ្ធផលដ៏ល្អគួរឱ្យកត់សម្គាល់ និង គួរជាទីមោទន នៅក្នុងការប្រមូលចំណូលថវិការដ្ឋ ក្នុងរយៈពេល ៥

ឆ្នាំចុងក្រោយនេះ គួបផ្សំជាមួយនឹងការចាត់ចែងដោយមធ្យ័ត, វិន័យហ្មឺងម៉ាត់ និង ប្រកបដោយប្រសិទ្ធភាពខ្ពស់ នូវចំណាយសាធារណៈរបស់រដ្ឋ, ទាំងក្នុងទិដ្ឋភាពវិភាជន៍ ទាំងក្នុងទិដ្ឋភាពប្រតិបត្តិការ, រួមទាំងការដាក់ចេញយ៉ាងទាន់ពេល និង ប្រកបដោយភាពរស់រវើក នូវវិធានការធ្វើវិចារណកម្មចំណាយរបស់ក្រសួង-ស្ថាប័នរដ្ឋ នៅអំឡុងពេលវិបត្តិជំងឺកូវីដ-១៩ នេះផង ។

## សម្ដេច, ឯកឧត្តម, លោកជំទាវ, លោក, លោកស្រី !

ជាការពិត, កត្តាដ៏សំខាន់ និង ចាំបាច់បំផុតមួយ ដើម្បីធានាបាននូវភាពជោគជ័យនៃការដាក់ឱ្យដំណើរការកម្មវិធីឧបត្ថម្ភសាច់ប្រាក់នេះ គឺ **«ការកំណត់អត្តសញ្ញាណគ្រួសារក្រីក្រ»** ដែលជាបុរេលក្ខខណ្ឌមិនអាចខ្វះបាន សម្រាប់ធានាថា **«ពលរដ្ឋក្រីក្រពិតប្រាកដ នឹងទទួលបានអត្ថប្រយោជន៍ពិតប្រាកដ»** ពីកម្មវិធីឧបត្ថម្ភសាច់ប្រាក់នេះ ។ ផ្អែកលើរចនាសម្ព័ន្ធការងារដែលមានស្រាប់, ក្រុមការងារអន្តរក្រសួងបានសម្រេចប្រើប្រាស់ប្រព័ន្ធកំណត់អត្តសញ្ញាណគ្រួសារក្រីក្ររបស់ក្រសួងផែនការ ជាយន្តការសម្រាប់ការកំណត់អត្តសញ្ញាណអ្នកទទួលផល ។ លើមូលដ្ឋាននេះ, ក្រសួងផែនការបានដឹកនាំធ្វើបច្ចុប្បន្នភាពជាបន្ទាន់ លើទិន្នន័យដែលមានស្រាប់ក្នុងគោលបំណងកាត់បន្ថយជាអតិបរមានូវភាពខ្វះចន្លោះនានា, ជាពិសេស គឺការកំណត់ឱ្យបានច្បាស់លាស់ នូវ «**ក្រុមគ្រួសារក្រីក្រពិតប្រាកដ**» ដែលមិនទទួលបានបំណ្ណសមធម៌ ទៅតាមគោលនយោបាយដែលរាជរដ្ឋាភិបាលបានដាក់ចេញ ។ ផ្អែកតាមលទ្ធផលនៃការធ្វើបច្ចុប្បន្នភាពក្នុងជុំទី ១, យើងមានប្រជាពលរដ្ឋដែលស្ថិតនៅក្នុងចំណាត់ថ្នាក់ «**ក្រ-១**» **ចំនួន ២១១ ៧៤៦ គ្រួសារ** និង «**ក្រ-២**» **ចំនួន ៣៥០ ៩៤០ គ្រួសារ** ។

ក្រៅពីកម្រិតនៃភាពក្រីក្រដែលជាមូលដ្ឋានសម្រាប់ការផ្តល់ប្រាក់ឧបត្ថម្ភ, ក្រុមការងារចំពោះកិច្ច ក៏បានស្នើឱ្យមានការគិតគូរបន្ថែមអំពីកត្តាសមធម៌ ដោយពិនិត្យមើលលើភាពងាយរងគ្រោះរបស់គ្រួសារនីមួយៗ ក្នុងនោះរួមមាន : កុមារអាយុក្រោម ៥ ឆ្នាំ, ជនមានពិការភាព, ជនចាស់ជរាអាយុចាប់ពី ៦០ ឆ្នាំឡើង និង អ្នកផ្ទុកមេរោគអេដស៍ ព្រមជាមួយនឹងការគិតគូរបែងចែកតាមតំបន់ (រាជធានី-ទីក្រុង និង ជនបទ) ដើម្បីឆ្លើយតបទៅនឹងភាពខុសគ្នានៃថ្លៃទំនិញរវាងតំបន់នីមួយៗ ។ រីឯការបើកផ្តល់ប្រាក់ឧបត្ថម្ភ គឺនឹងត្រូវបានធ្វើឡើងដោយប្រើ-ប្រាស់យន្តការ និង ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន ដែលកំពុងត្រូវបានប្រើប្រាស់ក្នុងការបើកផ្តល់ នៅ

ក្នុងកម្មវិធីឧបត្ថម្ភសាច់ជូនស្ត្រីមានផ្ទៃពោះ និង កុមារក្រោមអាយុក្រោម ២ ឆ្នាំ ដោយបែង-ចែកយ៉ាងច្បាស់លាស់ នូវការទទួលខុសត្រូវរបស់ស្ថាប័នពាក់ព័ន្ធនីមួយៗ ដើម្បីធានាបាននូវប្រតិតុល្យការ ។

ជារួម, ការផ្តល់ប្រាក់ឧបត្ថម្ភក្នុងកម្មវិធីនេះ មានដូចខាងក្រោម ៖

**១. តំបន់ទីប្រជុំជនក្នុងរាជធានីភ្នំពេញ**

**សម្រាប់ប័ណ្ណ«ក្រ-១»** ៖ ក្នុង ១ គ្រួសារ ទទួលបានប្រាក់ចំនួន ១២០ ០០០៛ (១២ ម៉ឺនរៀល) បូកបន្ថែម ៥២ ០០០៛ (៥ ម៉ឺន ២ ពាន់រៀល) សម្រាប់សមាជិកគ្រួសារម្នាក់ៗ ហើយបូកបន្ថែម ៤០ ០០០៛ (៤ ម៉ឺនរៀល) ម្នាក់ទៀត សម្រាប់សមាជិកនៅក្នុងគ្រួសារ ដែលជាកុមារអាយុក្រោម ៥ ឆ្នាំ, ជនមានពិការភាព, ជនចាស់ជរាអាយុចាប់ពី ៦០ ឆ្នាំឡើង និង អ្នកផ្ទុក មេរោគអេដស៍ ។

**សម្រាប់ប័ណ្ណ «ក្រ-២»**៖ ក្នុង ១ គ្រួសារ ទទួលបានប្រាក់ចំនួន ១២០ ០០០៛ (១២ ម៉ឺនរៀល) បូកបន្ថែម ៣៦ ០០០៛ (៣ ម៉ឺន ៦ ពាន់រៀល) សម្រាប់សមាជិកគ្រួសារម្នាក់ៗ ហើយ បូកបន្ថែម ២៨ ០០០៛ (២ ម៉ឺន ៨ ពាន់រៀល) ម្នាក់ទៀត សម្រាប់សមាជិកនៅក្នុងគ្រួសារ ដែលជាកុមារអាយុក្រោម ៥ ឆ្នាំ, ជនមានពិការភាព, ជនចាស់ជរាអាយុចាប់ពី ៦០ ឆ្នាំឡើង និង អ្នកផ្ទុកមេរោគអេដស៍ ។

**២. តំបន់ទីប្រជុំជនក្រៅពីរាជធានីភ្នំពេញ**

**សម្រាប់ប័ណ្ណ «ក្រ-១» ៖** ក្នុង ១ គ្រួសារទទួលបានប្រាក់ចំនួន ១២០ ០០០៛ (១២ ម៉ឺនរៀល) បូកបន្ថែម ៤០ ០០០៛ (៤ ម៉ឺនរៀល) សម្រាប់សមាជិកគ្រួសារម្នាក់ៗ ហើយ បូកបន្ថែម ៤០ ០០០៛ (៤ ម៉ឺនរៀល) ម្នាក់ទៀត សម្រាប់សមាជិកនៅក្នុងគ្រួសារ ដែលជាកុមារអាយុក្រោម ៥ ឆ្នាំ, ជនមានពិការភាព, ជនចាស់ជរាអាយុចាប់ពី ៦០ ឆ្នាំឡើង និង អ្នកផ្ទុកមេរោគអេដស៍ ។

**សម្រាប់ប័ណ្ណ «ក្រ-២» ៖** ក្នុង ១ គ្រួសារទទួលបានប្រាក់ចំនួន ១២០ ០០០៛ (១២ ម៉ឺនរៀល) បូកបន្ថែម ២៨ ០០០៛ (២ ម៉ឺន ៨ ពាន់រៀល) សម្រាប់សមាជិកគ្រួសារម្នាក់ៗ ហើយបូកបន្ថែម ២៨ ០០០៛ (២ ម៉ឺន ៨ ពាន់រៀល) ម្នាក់ទៀត សម្រាប់សមាជិកនៅក្នុង

គ្រួសារ ដែលជាកុមារអាយុក្រោម ៥ ឆ្នាំ, ជនមានពិការភាព, ជនចាស់ជរាអាយុចាប់ពី ៦០ ឆ្នាំ ឡើង និង អ្នកផ្ទុកមេរោគអេដស៍ ។

**៣. តំបន់ជនបទ**

**សម្រាប់ប័ណ្ណ «ក្រ-១» ៖** ក្នុង ១ គ្រួសារទទួលបានប្រាក់ចំនួន ៨០ ០០០៛ (៨ ម៉ឺន រៀល) បូកបន្ថែម ២៤ ០០០៛ (២ ម៉ឺន ៤ ពាន់រៀល) សម្រាប់សមាជិកគ្រួសារម្នាក់ៗ ហើយបូកបន្ថែម ២៤ ០០០៛ (២ ម៉ឺន ៤ ពាន់រៀល) ម្នាក់ទៀត សម្រាប់សមាជិកនៅក្នុង គ្រួសារ ដែលជាកុមារអាយុក្រោម ៥ ឆ្នាំ, ជនមានពិការភាព, ជនចាស់ជរាអាយុចាប់ពី ៦០ ឆ្នាំ ឡើង និង អ្នកផ្ទុកមេរោគអេដស៍ ។

**សម្រាប់ប័ណ្ណ «ក្រ-២» ៖** ក្នុង ១ គ្រួសារទទួលបានប្រាក់ចំនួន ៨០ ០០០៛ (៨ ម៉ឺន រៀល) បូកបន្ថែម ១៦ ០០០៛ (១ ម៉ឺន ៦ ពាន់រៀល) សម្រាប់សមាជិកគ្រួសារម្នាក់ៗ ហើយបូកបន្ថែម ១៦ ០០០៛ (១ ម៉ឺន ៦ ពាន់រៀល) ម្នាក់ទៀត សម្រាប់សមាជិកនៅក្នុង គ្រួសារ ដែលជាកុមារអាយុក្រោម ៥ ឆ្នាំ, ជនមានពិការភាព, ជនចាស់ជរាអាយុចាប់ពី ៦០ ឆ្នាំ ឡើង និង អ្នកផ្ទុកមេរោគអេដស៍ ។

**សម្តេច, ឯកឧត្តម, លោកជំទាវ, លោក, លោកស្រី !**

ខ្ញុំសូមជម្រាបជូនបន្ថែមថា ការរៀបចំដាក់ឱ្យដំណើរការនូវ «**កម្មវិធីឧបត្ថម្ភសាច់ប្រាក់ជូនគ្រួសារក្រីក្រ និង ងាយរងគ្រោះ ក្នុងអំឡុងពេលជំងឺកូវីដ-១៩**» បានទទួលការយកចិត្តទុកដាក់ និង កិច្ចសហការយ៉ាងល្អ ពីសំណាក់បណ្តាក្រសួង-ស្ថាប័នពាក់ព័ន្ធនៃរាជរដ្ឋាភិបាល ប្រកបដោយស្មារតីជាម្ចាស់ ។ យើងក៏បានទទួលនូវការគាំទ្រយ៉ាងសកម្មពីសំណាក់ដៃគូអភិវឌ្ឍន៍នានាផងដែរ ។ ដូច្នេះ, ខ្ញុំសូមឆ្លៀតយកឱកាសនេះ ថ្លែងអំណរគុណយ៉ាងជ្រាល-ជ្រៅចំពោះកិច្ចសហការ និង ការចូលរួមជាមតិយោបល់នានា ពីសំណាក់ក្រសួង-ស្ថាប័ន និង ដៃគូពាក់ព័ន្ធទាំងអស់ ដែលជាប្រការនាំឱ្យយើងអាចសម្រេចបាននូវលទ្ធផលដ៏ល្អនាពេលនេះ ។

**សម្តេចតេជោ នាយករដ្ឋមន្ត្រី** ជាទីគោរពដ៏ខ្ពង់ខ្ពស់បំផុត ! ខ្ញុំសូមសម្តែងនូវវន្ទនកិច្ច និង កត្តញ្ញុតាធម៌ដ៏យ៉ាងជ្រាលជ្រៅបំផុត, ជាថ្មីម្តងទៀត គោរពជូនចំពោះ **សម្តេច**

ដែល **សម្តេច** បានផ្តល់កិត្តិយសដ៏ខ្ពង់ខ្ពស់បំផុត ក្នុងការដាក់ឱ្យដំណើរការនូវកម្មវិធីជំនួយសង្គមដ៏មានសារៈសំខាន់នេះ ។ ប្រការនេះ សបញ្ជាក់យ៉ាងប្រចក្ស អំពីការយកចិត្តទុកដាក់ខ្ពស់បំផុតរបស់ **សម្តេច** មកលើសុខទុក្ខរបស់ប្រជាជន ក្នុងគ្រប់កាលៈទេសៈ ពិសេស ក្នុងខណៈដែលប្រទេសជាតិ និង ប្រជាជន ត្រូវជួបប្រឈមនឹងការលំបាក ។

ជាទីបញ្ចប់, ខ្ញុំសូមគោរពជូនពរដល់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា,** សម្តេច, ឯកឧត្តម, លោកជំទាវ, លោក, លោក-ស្រី, ភ្ញៀវជាតិ និង អន្តរជាតិ គ្រប់រូប សូមប្រកបដោយសុខភាពល្អ, កម្លាំងមាំមួន, សម្រេចបានជោគជ័យក្នុងគ្រប់ភារកិច្ច និង ទទួលបាននូវសុភមង្គលក្នុងក្រុមគ្រួសាររៀងៗខ្លួន ។

ជាកិច្ចបន្ត, ខ្ញុំសូមអនុញ្ញាតគោរពអញ្ជើញ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** ឡើងថ្លែង **សុន្ទរកថាគន្លឹះ** ប្រកាសដាក់ឱ្យដំណើរការជាផ្លូវការ នូវ «**កម្មវិធីឧបត្ថម្ភសាច់ប្រាក់ជូនគ្រួសារក្រីក្រ និង ងាយរងគ្រោះ ក្នុងអំឡុងពេលជំងឺកូវីដ-១៩**» ។

**សូមគោរពអញ្ជើញ សម្តេច** !